# ការកសាងប្រទេសកម្ពុជាអោយឆ្លងផុតវិបត្តិ — ការពង្រឹងវិស័យសំខាន់ៗដើម្បីកំណើននៅអនាគតការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ: ទេសចរណ៍

*អត្ថបទនេះ សង្ខេបចេញពីបទបង្ហាញរបស់ ឯកឧត្តម ទិត ចន្ថា, លោក Jean-Daniel Gardère និង លោក ហូ វណ្ណី[១] នៅក្នុងវគ្គទី៣ក (២) នៃសន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៩ ។*

## វិស័យទេសចរណ៍នៅកម្ពុជា: កំណើន និងការរួមចំណែកក្នុងសេដ្ឋកិច្ច

ទេសចរណ៍ គឺជាវិស័យគន្លឹះសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ។ ចំពោះកម្ពុជា វិស័យនេះ គឺជាស្ទាបចក្រមួយក្នុងចំណោមស្ទាបចក្រទាំងបួននៃកំណើន ។ តាមការសិក្សាមួយរបស់ធនាគារពិភពលោក វិស័យទេសចរណ៍រួមចំណែក ០,៥%នៃកំណើន ផសស ក្នុងអំឡុងឆ្នាំ១៩៩៨-២០០៧ ។ នៅឆ្នាំ២០០៧ វាមានចំណែក ៤% ក្នុង ផសស ។ ទេសចរណ៍ ក៏ជាវិស័យបង្កើតចំណូលដ៏ចំបងមួយសំរាប់សេដ្ឋកិច្ចជាតិដែរ ហើយវាដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការងារ ការបង្កើតប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រ ។ វិស័យនេះ ជួយលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំង ពង្រឹងការអភិរក្សវប្បធម៌ និងធនធានធម្មជាតិ ។

ការរីកលូតលាស់យ៉ាងលឿននៃវិស័យទេសចរណ៍នៅកម្ពុជា អាចបានមកពីកត្តាជាច្រើន ក្នុងនេះកត្តាដ៏សំខាន់មួយ គឺ ឧត្តមភាពប្រកួតប្រជែងមានស្រាប់ ពោលគឺ ប្រាសាទអង្គរវត្ត ។ ក្រៅពីសម្បត្តិដ៏វិសេសនេះ កម្ពុជានៅមានកេរ្តិ៍ដំណែលវប្បធម៌ និងសម្បត្តិធម្មជាតិជាច្រើន មានទីតាំងដ៏ល្អនៅក្នុងតំបន់ ព្រមទាំង គោលនយោបាយបើកចំហជើងមេឃ ដែលបានជួយសម្រួល និងពង្រឹងដល់កំណើនទេសចរណ៍នេះ ។ ការកសាងបានសន្តិភាព និងស្ថិរភាព គឺជាមូលហេតុមួយទៀត នៃកំណើនលំហូរចូលភ្ញៀវទេសចរ ។

វិស័យទេសចរណ៍មានចំណុចខ្សោយពីកំណើតមួយ ភាពងាយរងគ្រោះខ្លាំងដោយសារការវិវត្តមិនអំណោយផលខាង បរិស្ថាន សង្គមកិច្ច-វប្បធម៌ សេដ្ឋកិច្ច ឬ នយោបាយ ។ ចំណុចនេះមានន័យថា គេត្រូវគ្រប់គ្រងលើវិស័យទេសចរណ៍ដោយប្រុងប្រយ័ត្ន និងមានចីរភាព កុំឱ្យវាបំផ្លាញខ្លួនវាបាន ។

## ផលប៉ះពាល់នៃវិបត្តិលើទេសចរណ៍ក្នុងស្រុក និងសាកលលោក

ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក បង្ហាញពីភាពងាយរងគ្រោះជៀសមិនរួចនៃវិស័យទេសចរណ៍ ចំពោះការវិវត្តនៅខាងក្រៅ ។ នៅឆ្នាំ២០០៨ វិស័យទេសចរណ៍ពិភពលោក ស្ទើរតែគ្មានលូតលាស់សោះ ដោយកើនឡើងតាមអត្រាបាន់ស្មានត្រឹម ២% ប៉ុណ្ណោះ សំរាប់ភ្ញៀវទេសចរសរុប ៩២៤លាននាក់ ។ វិស័យទេសចរណ៍នៅសហភាពអឺរ៉ុប កើនតែ ០,១% ប៉ុណ្ណោះ ដោយមានភ្ញៀវទេសចរមកដល់ ៤៨៨លាននាក់ រីឯ នៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក វាកើន ១,៦% ដោយមានទេសចរមកដល់ប្រហែល ១៨៨លាននាក់ ។ឥទ្ធិពលនៃវិបត្តិនេះ ក៏ធ្លាក់មកលើកម្ពុជាដែរ ។ នៅឆ្នាំ២០០៨ ភ្ញៀវទេសចរមកដល់កម្ពុជា កើន ៥,៥% ( ក្រាហ្វិក ១) ដែលមានភាពអាប់អួរជាងមុន បើធៀបនឹងកំណើនប្រចាំឆ្នាំជាមធ្យម ២៥% ក្នុងពេលកន្លងមក ។ នៅខែមីនា ២០០៨ កំណើនភ្ញៀវទេសចរ បានចាប់ផ្តើមធ្លាក់ចុះគួរឱ្យកត់សំគាល់ ហើយសមាសភាព និងរបៀបមកដល់នៃភ្ញៀវទេសចរ ក៏ផ្លាស់ប្តូរខ្លះដែរ ។ ចំនួនភ្ញៀវទេសចរជនជាតិកូរ៉េ ធ្លាក់ចុះអស់ ១៩% ដោយសារសេដ្ឋកិច្ចប្រទេសកូរ៉េកាន់តែរួមចុះខ្លាំងឡើង ។ ការធ្លាក់ចុះទេសចរកូរ៉េនេះ ត្រូវបានប៉ះប៉ូវវិញដោយកំណើនភ្ញៀវទេសចរមកពីសហភាពអឺរ៉ុប និងតំបន់អាស៊ាន ។ កាលពីឆ្នាំមុន ភ្ញៀវទេសចរមកដល់តាមផ្លូវអាកាស ថយចុះ ៤,៤% ហើយអាកាសយានដ្ឋានសៀមរាបមានការធ្លាក់ចុះអ្នកដំណើរអស់ ១២% ។ ការធ្លាក់ចុះចំនួនមកដល់តាមផ្លូវអាកាស ត្រូវបានប៉ះប៉ូវវិញ ដោយកំណើនភ្ញៀវមកតាមផ្លូវគោក និងផ្លូវទឹក ។

ផ្អែកលើទិន្នន័យជាដំបូងៗ ភ្ញៀវទេសចរមកដល់ បន្តថយចុះអស់ ២% ទៀតនៅខែមករា ២០០៩ ។ ជារួម គេបានទស្សទាយថា វិស័យទេសចរណ៍នឹងជួបការលំបាកតឹងតែងក្នុងឆ្នាំ២០០៩ នេះ ហើយតាមការព្យាករណ៍មួយចំនួនភ្ញៀវទេសចរមកដល់កម្ពុជា នឹងធ្លាក់ចុះអស់ ៣% ដោយមានការបាត់បង់ទេសចរអស់ប្រហែល ៦៣.០០០នាក់ ប្រាក់ចំណូល ៥៣លានដុល្លារ និង ១០.០០០ការងារដែលទាក់ទងផ្ទាល់នឹងទេសចរណ៍ ។ ការប៉ាន់ស្មានមួយទៀតបានអះអាងថា សកម្មភាពទេសចរណ៍នៅរដូវមមាញឹក នឹងធ្លាក់ចុះអស់ ១៥% ក្នុងឆ្នាំ២០០៨-២០០៩ ។ ទីភ្នាក់ងារទេសចរណ៍ និងម្ចាស់សណ្ឋាគារជាច្រើនបានសម្តែងការព្រួយបារម្ភរួចហើយពីការថយចុះយ៉ាងច្រើននៃភ្ញៀវទេសចរដែលទាក់ទងសាកសួរព័ត៌មាន និងកក់កន្លែងទុក នៅឆ្នាំនេះ ។ទោះយ៉ាងនេះក្តី ដៃគូសហការណ៍មួយចំនួន នៅតែមានគំនិតសុទិដ្ឋិនិយមដដែល ហើយរដ្ឋាភិបាលបានព្យាករណ៍ថា វិស័យទេសចរណ៍នឹងបន្តរីកលូតលាស់នៅឆ្នាំនេះ ។ ក្រុមអ្នកវិភាគពីទេសចរណ៍មួយចំនួន បានយល់ស្របថានឹងមានការធ្លាក់ចុះ ប៉ុន្តែក្នុងកំរិតមិនគួរបារម្ភពេកទេ ។ បញ្ហាប្រឈមនៅឆ្នាំនេះមានធំៗណាស់ ប៉ុន្តែមិនមែនពុះពារមិនបាននោះទេ ។ ពិតហើយ ឱកាសល្អនៅមានច្រើនដែលអាចកែប្រែស្ថានភាពអាប់អួរឱ្យប្រសើរឡើងវិញ ដូចជា ជនជាតិអាមេរិក ជប៉ុន និងអឺរ៉ុប ប្រហែលកើនទឹកចិត្តធ្វើដំណើរកំសាន្ត ពីព្រោះប្រាក់ដុល្លារ ប្រាក់យេន និងប្រាក់អឺរ៉ូ បានឡើងថ្លៃ ។ ការធ្វើដំណើរចេញពីប្រទេសចិន និងឥណ្ឌា ក៏រំពឹងថាបន្តកើនឡើងដែរ ដោយសារសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ នៅតែមានកំណើន ។ គេរំពឹងទុកថា ការធ្វើដំណើរកំសាន្តក្នុងស្រុក និងក្រៅស្រុកក្នុងរយៈពេលខ្លី នឹងកើនឡើង ដោយហេតុថាមានប្រជាជនជាច្រើនចង់ធ្វើដំណើរទៅតំបន់មិនឆ្ងាយពីផ្ទះ ដូច្នេះដំណើរក្នុងស្រុក ឬទៅអន្តរជាតិក្នុង រយៈពេលខ្លី រំពឹងថានឹងកើនឡើង ។ ដោយមូលហេតុនេះ វិបត្តិទំនងមិនប៉ះពាល់ស្មើៗគ្នាទៅគ្រប់កន្លែងនោះទេ ។ វាជះឥទ្ធិពលខ្លាំងជាងគេទៅលើកញ្ចប់ទស្សនកិច្ចប្រណិត រីឯខ្សែទស្សនកិច្ចដែលផ្តល់សេវាមិនសូវថ្លៃវិញ គេរំពឹងថាអាចទ្រាំទ្រនឹងវិបត្តិបានប្រសើរជាងច្រើន ។

## ការធ្លាក់ចុះនៃវិស័យទេសចរណ៍ក្នុងស្រុក: កត្តាផ្សេងៗ

វិបត្តិសាកល ដែលបានកាត់បន្ថយទ្រព្យធន ប្រាក់ចំណូល និងទំនុកចិត្ត គឺជាកត្តាចំបងនៃការធ្លាក់ចុះវិស័យទេសចរណ៍កម្ពុជា ។ នៅមានកត្តាផ្សេងៗជាច្រើនទៀតដែលបានរួមចំណែកក្នុងការធ្លាក់ចុះនេះដែរ ដូចជា ជំលោះ

---

១ ឯកឧត្តម ទិត ចន្ថា ជាអគ្គនាយកទេសចរណ៍នៃក្រសួងទេសចរណ៍, លោក Jean-Daniel Gardère ជាទីប្រឹក្សាជាន់ខ្ពស់ ហើយ លោក ហូ វណ្ណី ជាសហប្រធានក្រុមការងារវិស័យឯកជន ស្តីពីវិស័យទេសចរណ៍ និងជានាយកគ្រប់គ្រងទីភ្នាក់ងារទេសចរណ៍ World Express Tours and Travel Co.Ltd.

ក្រាហ្វិក ២: ភ្ញៀវទេសចរមកដល់កម្ពុជា ១៩៩៣-២០០៨




ព្រំដែន កម្ពុជា-ថៃ ដែលបានជះឥទ្ធិពលដល់ពាណិជ្ជកម្មឆ្លងដែនរវាងប្រទេសទាំងពីរ ។ កត្តាមួយទៀត គឺជំលោះផ្ទៃក្នុងនយោបាយប្រទេសថៃ ដែលបណ្ដាលឱ្យអាកាសយានដ្ឋានធំមួយនៅថៃត្រូវបិទទ្វារមិនដំណើរការ កាលពីឆ្នាំកន្លងទៅ ។ ដោយសារថៃ ជាច្រកចូលដ៏សំខាន់មួយសំរាប់ទេសចរមកកាន់ប្រទេសកម្ពុជា ដូច្នេះជំលោះនយោបាយនៅថៃមានផលប៉ះពាល់អវិជ្ជមានមកលើទេសចរណ៍កម្ពុជា ។

សំខាន់ជាងនេះទៀត មានការវិភាគស៊ីជម្រៅមួយបង្ហាញថា ការរីកលូតលាស់យ៉ាងលឿននៃទេសចរណ៍ក្នុងពេលកន្លងមក ពិតជាមិនអាចមានចីរភាពទេ ។ ទោះជាមាន ឬមិនមានវិបត្តិក្ដី ការរលំរលាយនៃកំណើនទេសចរណ៍ ត្រូវតែកើតមានឡើង ក្នុងរយៈពេល ២-៣ឆ្នាំបន្ទាប់មក ។ ប្រាសាទអង្គរវត្ត ពិតជាបានរួមចំណែកមួយផ្នែក នៅក្នុងកង្វះចីរភាពទេសចរណ៍នេះ ។ អង្គរវត្តអាចជាចំនុចខ្លាំងជាងគេនៃទេសចរណ៍កម្ពុជា ប៉ុន្តែក៏បានក្លាយជាប្រភពចំបងមួយនៃភាពទន់ខ្សោយរបស់ទេសចរណ៍ដែរ ពីព្រោះមកទល់ពេលនេះ ប្រាសាទអង្គរវត្តបានទាក់ទាញ ស្ទើរតែផ្ដាច់មុខនូវចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរ ដូច្នេះហើយក៏បានប៉ះពាល់ដល់កន្លែងទេសចរណ៍ឯទៀត ។ មូលហេតុមួយផ្សេងទៀតនៃកង្វះចីរភាពទេសចរណ៍ គឺ ការប្រឹងជំរុញតែទេសចរណ៍ទ្រង់ទ្រាយធំ ជាជាងខំបង្កើនតំលៃបន្ថែមនៃសេវាកម្ម និងផលិតផលក្នុងវិស័យនេះ ។

## ចក្ខុវិស័យ និងគោលនយោបាយគួរអនុវត្តផ្សេងៗ

គេទស្សទាយថា វិស័យទេសចរណ៍នឹងរើបឡើងវិញនៅឆ្នាំ២០១០ ទោះបីមានឧបសគ្គជាច្រើនក៏ដោយ ។ គេត្រូវអនុវត្តតាមជំហានមួយចំនួនដើម្បីជួយទ្រទ្រង់ដល់ការរើបឡើងវិញនេះ និងមានជំហានជាច្រើនទៀតដើម្បីដោះស្រាយបញ្ហាចីរភាព ។ រដ្ឋាភិបាល និងដៃគូនានាខាងទេសចរណ៍ មានជំរើសគោលនយោបាយមួយចំនួន សំរាប់ដោះស្រាយបញ្ហាចីរភាពនេះ (ក្រាហ្វិក ២) ដែលឈរលើគោលគំនិតពីរជាសំខាន់ ។ ទីមួយ ត្រូវចងចាំថា ទ្រព្យសម្បត្តិដ៏ល្អឯកដូចជាអង្គរវត្តជាដើម ងាយទទួលរងការខូចខាតណាស់ ដូច្នេះត្រូវគ្រប់គ្រងទ្រព្យទាំងនេះ ដោយយកចិត្តទុកដាក់បំផុតតាមរយៈការលើកកំពស់គុណភាព និងភាពខុសប្លែកពីគេ ដើម្បីរក្សាកំលាំងប្រកួតប្រជែងរបស់ប្រាសាទឱ្យបានគង់វង្សយូរអង្វែង ។ ទីពីរ ត្រូវកត់សំគាល់ជាសំខាន់ថា ភ្ញៀវទេសចរច្រើនពេក ធ្វើឱ្យវិស័យទេសចរណ៍ស្លាប់ នៅស្ពឹកស្រពន់ ... ទ្រឹង ឬធ្លាក់ចុះវិញ ជាពិសេសនៅតាមកន្លែងដែលមិនសមស្របសំរាប់ទទួលមនុស្សច្រើនៗ ឬទទួលសកម្មភាពលំហែកំសាន្តបែបស្តង់ដារ និងទ្រង់ទ្រាយធំ ។ ទេសចរណ៍ទ្រង់ទ្រាយធំ មិនមែនចេះតែធ្វើបានគ្រប់ពេលវេលានោះទេ ហើយការជំរុញសកម្មភាពនេះឱ្យខាងតែបាន អាចធ្វើឱ្យខូចខាត ជាជាងផ្ដល់ផលចំណេញដល់វិស័យទេសចរណ៍ ។ ការកាត់បន្ថយកំរៃទេសចរណ៍ និងចំណាយផ្សេងៗដើម្បីទាក់ទាញ ភ្ញៀវទេសចរ ក៏គួរគិតគូរឡើងវិញដែរ ព្រោះមានការវាយតំលៃថា យុទ្ធសាស្ត្រនេះប្រហែលមិនផ្ដល់ ផលចំណេញអ្វីជាដុំកំភួនទេ ដោយសារហេតុផលជាច្រើន ។ ទីមួយ កំរៃ ពន្ធ និងចំណាយផ្សេងៗនៅក្នុងទេសចរណ៍កម្ពុជា មានកំរិតមិនខ្ពស់ទេ បើធៀបនឹងស្តង់ដារអន្តរជាតិ ។ លើសពីនេះទៀត ភ្ញៀវទេសចរមកពីបស្ចិមប្រទេស និងតំបន់អាស៊ី ដែលស្ថិតក្នុងទីផ្សារទេសចរណ៍ថ្នាក់កណ្ដាល និងថ្នាក់ខ្ពស់ និងដែលកម្ពុជាកំពុងចង់បានខ្លាំង ពួកគេពេញចិត្តបង់ថ្លៃខ្ពស់ថែមទៀត ឱ្យតែបានសេវាកម្មទេសចរណ៍មានគុណភាពល្អ ។ សុវត្ថិភាព ភាពស្អាតល្អមានអនាម័យ និងការចាត់ចែងទិដ្ឋាការបានលឿន គឺជាកត្តាមួយចំនួនទៀត ដែលទាក់ទាញភ្ញៀវទេសចរឱ្យចូលមកជាច្រើនដង ។ ដូច្នេះគេត្រូវតែប្រយ័ត្នប្រយែងចំពោះការអំពាវនាវឱ្យកាត់បន្ថយកំរៃទេសចរណ៍នេះ ពីព្រោះវាអាចនាំឱ្យមានការថយចុះថវិកាសំរាប់ចំណាយលើការថែទាំ និងការអនុវត្តគំនិតថ្មីៗ ហើយរឿងនេះអាចប៉ះពាល់ដល់គុណភាពនៃសម្បត្តិទេសចរណ៍ ។

ដូចអាចមើលឃើញក្នុងក្រាហ្វិក២ យុទ្ធសាស្ត្រគួរអនុវត្តមួយ គឺ ការជំរុញអេកូទេសចរណ៍ ប៉ុន្តែដើម្បីឱ្យវាមានប្រសិទ្ធភាពនៅកម្ពុជា គេមិនត្រូវមានមហិច្ឆតាខ្ពស់ពេកទេ ។ គោលនយោបាយគ្រប់ជ្រុងជ្រោយ សម្រាប់អេកូទេសចរណ៍ ទាមទារជាចាំបាច់នូវធនធានច្រើនណាស់ ដែលកម្ពុជាមិនមានទេ ព្រមទាំង រុក្ខជាតិ និងសត្វដ៏សំបូរដែលកម្ពុជាបានបាត់បង់អស់មួយភាគធំ ហើយក្នុងអំឡុងពេលមានសង្គ្រាម ។ ដើម្បីធ្វើការទាក់ទាញ ខាងអេកូឡូស៊ី រដ្ឋាភិបាលគួរផ្ដួចផ្ដើមគោលនយោបាយមួយផ្ដោតលើបុគ្គល និងក្រុមតូចៗ ។ ការអភិវឌ្ឍបន្ថែមនូវត្រីកោណ ក្រុងព្រះសីហនុ-ក្រុងភ្នំពេញ-ក្រុងសៀមរាប គឺជាវិធានការមួយទៀតដែលមានបង្ហាញក្នុង ក្រាហ្វិក២ ដែរ ។ ក្រុងព្រះសីហនុ ទាមទារការយកចិត្តទុកដាក់ច្រើនជាងគេ ពីព្រោះបានលូតលាស់យឺតជាងគោលដៅទេសចរណ៍ពីរទៀត ។ ដំណឹងល្អមួយគឺ ឥឡូវនេះអាកាសយានដ្ឋានក្រុងព្រះសីហនុដំណើរការបានហើយ ប៉ុន្តែដំណឹងមិនល្អ គឺ បញ្ហាផ្សេងៗដូចជា ការលុបចោលជើងហោះហើរតភ្ជាប់ ជាដើម គេមិនទាន់បានដោះស្រាយនៅឡើយទេ ។ ការអភិវឌ្ឍក្រុងព្រះសីហនុ ពិតជានឹងផ្ដល់ផលចំណេញយ៉ាងច្រើន ។ គេប៉ាន់ស្មានថា ការផ្ដល់ការស្នាក់នៅក្នុងតំបន់ក្រុងព្រះសីហនុនេះ អាចនាំឱ្យភ្ញៀវទេសចរបង្កើនរយៈពេលស្នាក់នៅប្រទេសកម្ពុជា បានពី ២ ទៅ ៤ ថ្ងៃ ។ តាមនេះយើងអាចសំរេចបាននូវ កំណើនតំលៃ និងសកម្មភាពទេសចរណ៍ ពី ១៥% ទៅ ២៥% ក្នុង ៥ឆ្នាំ ខាងមុខ ទោះបីជាចំនួនភ្ញៀវទេសចរមកដល់កម្ពុជា មិនកើនឡើងក្ដី ។

ប្រាសាទអង្គរវត្តល្អត្រចះខ្លាំងណាស់ សមជាកម្មវត្ថុនៃមោទនភាពរបស់ប្រជាជនកម្ពុជាមែន ។ ប៉ុន្តែ អង្គរវត្តដ៏ល្អត្រចះ ក៏ដូចជា ទេសចរណ៍កម្ពុជាទាំងមូល អាចមានចីរភាពទៅបាន លុះត្រាតែគេកាត់បន្ថយភាពពឹងពាក់ទៅលើប្រាសាទនេះ និងបង្កើនភាពប្លែកពីគេរបស់អង្គរវត្ត ។ ជាការពិតណាស់ កម្ពុជា គឺជា រាជាណាចក្រអច្ឆរិយ សំបូរទៅដោយសម្បត្តិ-ធនធានទាក់ទាញចិត្ត ដែលរង់ចាំតែការយកចិត្តទុកដាក់ និងទទួលស្គាល់តំលៃតែប៉ុណ្ណោះ ៕

## ក្រាហ្វិក ២: យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយបានលើកឡើង ដើម្បីធ្វើឱ្យវិស័យទេសចរណ៍មានចីរភាព

**ការធ្វើឱ្យកំណើនទេសចរណ៍មានចីរភាព**

- គោលការណ៍ចំនួនពីរ
- សញ្ញាសំគាល់ និងភាពវិសេសតែមួយក្នុងពិភពលោក ងាយខូចខាតណាស់
- បើអនុវត្តមិនសមស្របទេ ទេសចរណ៍ទ្រង់ទ្រាយធំ អាចធ្វើឱ្យខូចខាតដល់វិស័យទេសចរណ៍

| យុទ្ធសាស្ត្រទូទៅ | យុទ្ធសាស្ត្រជាក់លាក់ | |
|---|---|---|
| ការគ្រប់គ្រងប្រាសាទអង្គរវត្ត និងតំបន់ជុំវិញប្រកបដោយចីរភាព | ធ្វើចំរុះកម្មសកម្មភាពទេសចរណ៍ - ផ្តល់មូលនិធិអភិវឌ្ឍន៍ពិសេសមួយសំរាប់គោលបំណងនេះ | កែលំអផែនការរៀបចំទីក្រុង ភាពស្អាត និងការគ្រប់គ្រងទឹក |
| | ធ្វើឱ្យទស្សនកិច្ចដំណើរការ បានល្អបំផុត - កែលំអសេវាកម្មទៅសួនកំសាន្ត - ពង្រីកបញ្ជីជំរើស តាមគោលការណ៍ខាងលើ | ដំណើរទេសចរណ៍តាមការបញ្ជាទិញ - បើកដល់យប់ជ្រៅ - ប្តូរចុះឡើងនូវផ្លូវធ្វើដំណើរកំសាន្ត - សំបុត្រចូលទស្សនា រយ:ពេល កន្លះថ្ងៃ - សំបុត្រចូលទស្សនា រយ:ពេល ៧-១៤ ថ្ងៃ |
| | ដោះស្រាយបញ្ហាទំនើបភាវូបនីយកម្ម - អនុវត្តប្រើប្រព័ន្ធអតិពលកម្ម និងបរិក្ខារមានលក្ខណ:ងាយស្រួល សំរាប់ អ្នកប្រើប្រាស់ (ឧ. ការដឹកជញ្ជូន ការដាក់ភ្លើងបំភ្លឺ ការបំរើម្ហូបអាហារ និងភេសជ្ជ:នៅកន្លែងទេសចរណ៍ មគ្គុទេសក៍ស្វ័យប្រវត្តិ) | |
| ធ្វើពិពិធកម្មទីផ្សារ និងផលិតផល | ទេសចរណ៍ធំជាងមុន : តំបន់អាស៊ាន អាស៊ាន + ៣ និង ឥណ្ឌា រុស្ស៊ី តំបន់មជ្ឈិមបូព៌ា និងអឺរ៉ុប | ធ្វើការបញ្ចុះបញ្ចូលដល់ប្រជាជនកម្ពុជាដែលរស់នៅក្នុងស្រុក និងនៅឯបរទេស ឱ្យធ្វើដំណើរកំសាន្តក្នុងប្រទេសកម្ពុជាញឹកញាប់ជាងមុន |
| សម្រួលដល់ការធ្វើដំណើរ | ជំរុញល្បឿនការផ្តល់ ទិដ្ឋាការចេញ-ចូល បានច្រើនដង | បើកដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរជាតិ |
| | ភាពបត់បែនបានលើរយ:ពេលអនុញ្ញាតអោយស្នាក់នៅ | បើកដំណើរការនូវកន្លែងត្រួតពិនិត្យតាមព្រំដែនបន្ថែមទៀត |
| | ចរចារពីកិច្ចព្រមព្រៀងឆ្លងកាត់ព្រំដែនបន្ថែមទៀត | ពង្រឹងទំនាក់ទំនងផ្លូវអាកាស ផ្លូវទឹក និងផ្លូវគោក ក្នុងតំបន់ |
| បង្កើនកំលាំងប្រកួតប្រជែងដោយលើកស្ទួយរូបភាព ភាពទាក់ទាញ ភាពវិសេសខុសគេ និងច្រកចូលទៅដល់ | ពង្រឹងការអនុវត្តផែនការ រៀបចំទីក្រុង និងស្តង់ដារសាងសង់ | ភាពបត់បែនបានជាងមុន នូវសិទ្ធិកាន់កាប់អចលនទ្រព្យ ដោយជនបរទេស |
| | អនុវត្តការបែងចែកតំបន់ និងបទបញ្ញត្តិការពារតំបន់ទេសចរណ៍ និងសញ្ញាសំគាល់ | បង្កើតមូលនិធិសំរាប់ការសាងសង់ និងការពារផ្លូវថ្នល់ និងផ្លូវលំ ដែលអាចប្រើសំរាប់ដំណើរកំសាន្តខ្លីៗ ដំណើរតាមផ្លូវជើង និងតំបន់អេកូទេសចរណ៍ខ្នាតតូច |
| ជំរុញអេកូទេសចរណ៍ | ទីផ្សារគោលដៅ គួរមានទំហំតូច (បុគ្គល និងក្រុមតូចៗ) | អភិវឌ្ឍព័ត៌មានចាំបាច់ (ឧ. ផែនទីប្រាប់ផ្លូវថ្មីៗ) និង សម្ភារ:ជួយសម្រួលផ្សេងៗ |
| | ជំរុញអេកូទេសចរណ៍នៅតំបន់ភ្នំក្រវាញ-កោះកុង និងតំបន់ទេសចរណ៍ល្អៗនៅកោះក្បែរៗនោះ | |
| ជំរុញ និងអភិវឌ្ឍបន្ថែមនូវតំបន់ត្រីកោណទេសចរណ៍ សៀមរាប-ភ្នំពេញ-ក្រុងព្រះសីហនុ | បង្កើន និងកែលំអគុណភាពកន្លែងស្នាក់នៅ ជាពិសេសនៅក្រុងព្រះសីហនុ | កែលំអសេវាអាកាសចរ និង ដោះស្រាយបញ្ហា ដូចជា ការលុបចោលជើងហោះហើរតភ្ជាប់ ជាដើម |
| កែលំអ និងបង្កើនការធ្វើម៉ាឃីធីង | អនុម័តប្រើចំណងជើងពីរោះទាក់ទាញចិត្តសំរាប់យុទ្ធនាការ ឃោសនា (ឧ. កម្ពុជា-រាជាណាចក្រអច្ឆរិយ) | ធ្វើការផ្សព្វផ្សាយនៅក្នុងបណ្តាញព័ត៌មាន CNN, National Geographic និងប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសជាគោលដៅ |
| កសាងក្រុមប្រឹក្សាទេសចរណ៍ជាតិកម្ពុជា (សូមមើលសេចក្តីសង្ខេបនៃអត្ថបទរបស់ លោក ហូ វណ្ណី ស្តីពីមុខងារដែលបានលើកឡើង) | | |